**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

# កំណត់ហេតុប្រជុំ
## ស្តីពីស្ថានភាព នៃការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជាឆ្នាំ២០២៥

ថ្ងៃអង្គារ ប្រាំមួយរោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.ពីរពាន់ប្រាំរយហុកសិបប្រាំបី ត្រូវនឹងថ្ងៃទីដប់ប្រាំបី ខែកុម្ភៈ ឆ្នាំពីរពាន់ម្ភៃប្រាំ វេលាម៉ោងប្រាំបួននិងសូន្យៗ នាទីព្រឹក នៅទីស្តីការក្រសួងមហាផ្ទៃ មានបើកកិច្ចប្រជុំពិភាក្សារវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដឹកនាំដោយ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ជាមួយលោកស្រី **Kelly Geoghengan** តំណាងក្រសួងការបរទេសសហរដ្ឋអាម៉េរិក ទទួលបន្ទុករបាយការណ៍ លើការងារសិទ្ធិមនុស្ស និងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃស្ថានទូតសហរដ្ឋអាម៉េរិកប្រចាំកម្ពុជា។ ដោយមានសមាសភាពអញ្ជើញចូលរួម៖

-ឯកឧត្តម ហ៊ូ វុឌ្ឍី រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-លោកជំទាវ ឡុង សុផល្លី រដ្ឋលេខាធិកាក្រសួងកិច្ចការនារី
-លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ
-ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី អគ្គស្នងការរងនគរបាលជាតិ
-ឯកឧត្តម ឧត្តមសេនីយ៍ឯក អ៊ុក ហៃសីឡា អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍
-ឯកឧត្តម ហ៊ិន ភក្តី អគ្គនាយករង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-ឯកឧត្តម ឧត្តមសេនីយ៍ទោ សុខ នីត្យា ប្រធាននាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា
-ឯកឧត្តម ឧត្តមសេនីយ៍ទោ សុក សំបូរ ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារងនីតិជន
-លោកជំទាវ ប៉ែន ផល្លីកា ប្រធាននាយកដ្ឋាន ក្រសួងយុត្តិធម៌
-ឯកឧត្តម សេង សុជាតិ ប្រធាននាយកដ្ឋានច្បាប់ និងកុងស៊ុល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង គ.ជ.ប.ជ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងមន្ត្រីបច្ចេកទេស សរុបចំនួន ៣៦នាក់ (ស្រី ០៩នាក់)។

ជាកិច្ចចាប់ផ្តើម និងដំណើរការនៃកិច្ចប្រជុំ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការដ្ឋាន គ.ជ.ប.ជ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានមតិស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានលោកស្រី **Kelly Geoghengan** ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ និងឯកឧត្តម លោកជំទាវ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិភាក្សានេះ ហើយបានណែនាំតំណាងជំនាញក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ ដើម្បីធ្វើការឆ្លើយតបទៅនឹងសំណួរដែលសហរដ្ឋអាមេរិក បានដាក់ជាសំណួរមកលើកកម្ពុជា ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងឆ្នាំ២០២៤។

បន្ទាប់មកលោកស្រី **Kelly Geoghengan** បានថ្លែងថាឆ្លៀតក្នុងឱកាសនេះ ខ្ញុំចង់ជម្រាបជូនឯកឧត្តម លោកជំទាវ ដែនមានវត្តមានក្នុងកិច្ចប្រជុំនេះ រហូតមកដល់ពេលនេះសហការីរបស់នាងខ្ញុំបានប្រមូលព័ត៌មានដាក់ចូលក្នុងរបាយការណ៍ដើម្បីបូកសរុប ហើយរបាយការណ៍នេះចាប់ផ្តើមពីថ្ងៃទី០១ ខែមេសា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០២៤ ប៉ុន្តែខាងស្ថានទូតសហរដ្ឋអាមេរិកនៅកម្ពុជា មានការកិច្ចត្រូវដាក់ព័ត៌មានទាំងនេះនៅត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤។ ហើយព័ត៌មានបន្ថែមដែលគាត់អាចដាក់បញ្ចូលបាន នាងខ្ញុំស្នើសុំធ្វើការប្រជុំថ្ងៃនេះ គឺធ្វើយ៉ាងណាដើម្បីឱ្យរាជរដ្ឋាភិបាលកម្ពុជាមានឱកាសបង្ហាញ រំលិចសកម្មភាព និងចែករំលែកនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខុសពីរយៈពេលឆ្នាំមុនៗ។ ហើយខ្ញុំសង្ឃឹមថាទទួលបានព័តមានភាពច្បាស់លាស់ ធ្វើយ៉ាងណាដើម្បីឱ្យនាងខ្ញុំបានធ្វើការផ្សព្វផ្សាយព័ត៌មាននេះ ដូចដែលបានជម្រាបជូនឯកឧត្តម លោកជំទាវ ខាងលើរួចមកហើយ តាមពិតយើងត្រូវដាក់សេចក្តីពង្រាងដំបូងនៅចុងខែ ប៉ុន្តែមកដល់រយៈពេលនេះ ហេតុអ្វីបានជាយើងត្រូវស្វេះស្វែងរកព័ត៌មានពីក្រសួង ស្ថាប័នដែលបានស្នើសុំ។ ហើយការស្នើសុំ ការពន្យាពេលនឹងគឺមកពេលកំណត់ចុងសប្តាហ៍ខែកុម្ភៈនេះ ដើម្បីដាក់បញ្ចូលព័ត៌មានទៅកាន់មន្ត្រីក្រុមការងារវ៉ាស៊ីនតោន ដើម្បីធ្វើការវាយតម្លៃលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូររបស់កម្ពុជា។ ខ្ញុំមានចំណុចមួយចំនួននៅក្នុងកិច្ចប្រជុំថ្ងៃនេះ ចង់ផ្តោតទៅលើចំណុចសំខាន់ៗ គឺ**ចំណុចទី១** ចង់និយាយពីដំណើរការដែលទទួលបានព័ត៌មាន ខ្ញុំមានអារម្មណ៍ថាតិចជាងឆ្នាំមុន និងឆ្នាំមុនៗទៀត។ **ចំណុចទី២** ដែលចង់លើកមកពិភាក្សា កិច្ចសហប្រតិបត្តិការណ៍ធ្វើយ៉ាងណាការទទួលព័ត៌មានកាន់តែប្រសើឡើង។ **ចំណុចទី៣** ជាឱកាសដើម្បីឱ្យរាជ្យរដ្ឋាភិបាលកម្ពុជាមានការចែករំលែកនូវវីដេអូ ដូចជាពេលប្រជុំពេលនេះ មានរឿងជាច្រើនដែលរាជរដ្ឋាភិបាលកម្ពុជាបានឆ្លើយតប មិនថាបទល្មើសឆបោកតាមប្រព័ន្ធអនឡាញ ឬការជួញដូរមនុស្សទេ ប៉ុន្តែពេលខ្លះទៅលឺព័ត៌តាមសារព័ត៌មាន នឹងត្រូវចប់ត្រឹមសារព័ត៌មាន។ ដោយសារតែយើងអត់ទទួលបានព័ត៌មានលម្អិត ទាក់ទងទៅនឹងករណីមួយចំនួន ដែលបានឃើញថារាជរដ្ឋាកម្ពុជាយើងបានដោះស្រាយតាមរយៈសារព័ត៌មាន។ ខ្ញុំគិតថាមកដល់រយៈពេលថ្ងៃនេះ និងជាច្រើនសប្តាហ៍មុនសហការីរបស់នាងខ្ញុំ បានធ្វើការស្នើសុំព័ត៌មានពីក្រសួង ស្ថាប័នរួចមកហើយ ប៉ុន្តែបើជាសំណួរមិនច្បាស់ត្រង់ចំណុចណាវាជាឱកាសក្នុងការជួបពិក្សាក្នុងពេលនេះសម្រាប់ការបំពេញបន្ថែមនូវព័ត៌មានខ្វះខាត។

បន្ទាប់មកទៀតលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានប្រសាសន៍ថា ដូចដែលលោកស្រីបានលើកឡើងដែលថាព័ត៌មានពីខាងយើងទទួលបានតិច ដោយសារតែខាងកម្ពុជាបានស្នើទៅ គឺមានរយៈពេលត្រឹមតែប្រាំបួនខែប៉ុណ្ណោះ ប៉ុន្តែខាងក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ បានបន្តព្យាយាមផ្ញើមក អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាបន្តបន្ទាប់។ ក្រុមការងារនៃរបាយការណ៍កំពុងបន្តបូកសរុបដាក់ចូលក្នុងរបាយការណ៍ឆ្នាំ២០២៤ ហើយនៅចុងសប្តាហ៍ក្នុងខែកុម្ភៈ ឆ្នាំ២០២៥នេះ និងផ្ញើជូនសហរដ្ឋអាមេរិក ប៉ុន្តែហេតុអ្វីបានជាមិនទាន់បានផ្ញើជូន ដោយសារមិនទាន់បានសម្អាតទិន្នន័យរបស់ជនល្មើស។ កន្លងមកដែលយើងបានសង្កេតឃើញថា ដោយគិតមិនទាន់ដាច់ស្រាច់ពាក់ព័ន្ធការស្តេនជាមួយនឹងការជួញដូរមនុស្ស ដែលប្រព័ន្ធសារព័ត៌មាននៃបណ្តាប្រទេសតែងតែចោទប្រកាន់ ដោយបានដាក់បញ្ចូលសកម្មភាពស្កេននៅក្នុងអំពើជួញដូរមនុស្ស ដែលធ្វើឱ្យទិន្នន័យពីខាងក្រៅមានភាពធំហួសពីការពិត។ រឿងនេះហើយដែលយើងក៏ត្រូវការធ្វើការស្រាវជ្រាវ និងរកភាពច្បាស់លាស់ ដើម្បីធ្វើការបញ្ជាក់ ដោយបានចូលរួមជាមួយប្រទេសនានា ដើម្បីពិភាក្សាគ្នា ថាតើបញ្ហានេះមានច្បាប់បញ្ចូលគ្នាបានដោយរបៀបណា ប្រសិនបើជាយើងនៅប្រទេសកម្ពុជាវិញ គឺមានការកំណត់អត្តសញ្ញាណ ដែលធ្វើឱ្យមានការញែកទិន្នន័យរវាងអំពើជួញដូរមនុស្ស និងបទល្មើសផ្សេងទៀត។ ចំពោះគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺមានការទទួលខុសត្រូវអំពើជួញដូរមនុស្ស និងអ្វីៗដែលយើងបានរាយការណ៍ជូន និងព្យាយាមយកទិន្នន័យណាដែលជាអំពើជួញដូរមនុស្ស ដូច្នេះមិនបានឆ្លើយតបទាំងស្រុងពីការវាយប្រហាខាងក្រៅ

នោះទេ។ អ្វីដែលជាការលើកឡើងរបស់សហរដ្ឋអាមេរិក បានធ្វើការវាយតម្លៃឆ្នាំមុនដោយផ្អែកទៅលើអនុសាសន៍ដែលបានដាក់ចុះកាលពីឆ្នាំទៅ គឺក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ កំពុងតែប្រមូលព័ត៌មាន ដើម្បីដាក់ចូលក្នុងរបាយការណ៍សម្រាប់បញ្ជាក់បន្ថែម។ បន្ទាប់មកទៀតលោកជំទាវបានឱ្យតំណាងក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធធ្វើការបកស្រាយជូនលោកស្រីបន្ថែមទៀត។

លោកជំទាវ **ប៉ែន ផល្លីកា** ប្រធាននាយកដ្ឋាន ក្រសួងយុត្តិធម៌ បានលើកឡើងថាកាលពីឆ្នាំ២០២៣កន្លងទៅចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលអាមេរិកត្រូវការ គឺមាន១២មាត្រា មាន៥៤សំណុំរឿង និងបទល្មើសមិនពាក់ព័ន្ធ១២មាត្រានេះ មាន២៦៨សំណុំរឿង។ នៅឆ្នាំ២០២៤នេះ ដោយគិតចាប់គិតពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ដោយមិនបានញែកពីមាត្រាដែលអាមេរិកត្រូវការ)។ ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត មាន ៤០០សំណុំរឿង ចាត់ការរួច មាន៣១៨សំណុំរឿង និងសល់កំពង់ចាត់ការ មាន៤៧សំណុំរឿង។ និងចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត មាន១៥៤សំណុំរឿង ចាត់ការរួច មាន២៨៨សំណុំរឿង និងកំពង់ចាត់ការ មាន១៦៧សំណុំរឿង។ ចំពោះទិន្នន័យលម្អិត ខ្ញុំបានផ្ញើជូនសហការីលោកស្រីរួចហើយ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជីវ ផល្លី** អគ្គស្នងការរងនគរបានជាតិ បានចូលរួមចែករំលែកបទពិសោធន៍ទាក់ទងនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយការជួញដូរមនុស្ស មុននឹងឈានទៅដល់ការកំណត់អត្តសញ្ញាណជនរងគ្រោះ ក្រសួងមហាផ្ទៃបានបង្កើតបង្កើតគណៈបញ្ជាការ ដើម្បីប្រយុទ្ធប្រឆាំងបទល្មើសគ្រប់ទម្រង់នៅក្នុងខែតុលា ឆ្នាំ២០២៤។ អគ្គស្នងការដ្ឋាននគរបាលជាតិ បានបង្កើតក្រុមការងារជំនាញចំនួនបួន ដើម្បីធ្វើអន្តារគមន៍ និងប្រតិបត្តិការនៅតាមគោលដៅ ដែលស្នើឱ្យមានអន្តារគមន៍ ឬសំណូមពរដើម្បីឱ្យធ្វើការពិនិត្យនៅកន្លែងដែលសង្ស័យ ដូច្នេះក្នុងករណីដែលមានព័ត៌មាន ហើយព័ត៌មាននោះអាចផ្តល់ ឬដាក់តាមសំណើតាមផេកដែលអាចធ្វើការផ្ទៀងតបបាន និងចុះធ្វើការតាមសំណើ មានផេកក្រសួងមហាផ្ទៃ ផេករបស់សម្តេចក្រឡាហោម ដែលជាអតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ផេករបស់ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ផេករបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ផេករបស់នាយកដ្ឋានកណ្តាលសន្តិសុខ ហើយនាយកដ្ឋានកណ្តាលសន្តិសុខគឺមានហតឡាញ ដើម្បីទទួលពាក្យបណ្តឹងទទួលព័ត៌គ្រប់ស្ថានទូតទាំងអស់ ស្របពេលនេះក៏មានអតឡាញអគ្គស្នងការដ្ឋាននគរបាលជាតិ និងមានអតឡាញនិងផេករបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សំម្រាប់ទទួលព័ត៌មាន ដោមមានមន្ត្រីប្រចាំការ២៤ម៉ោងលើ២៤ម៉ោង។ នៅពេលដែលយើងទទួលបានព័ត៌មានពីសំណើអន្តារគមន៍ ឬសំណូមពរ គឺក្រុមការងារទាំងបួន របស់អគ្គស្នងការដ្ឋាននគរបាលជាតិបានចុះទៅពិនិត្យទៅដល់កន្លែងកើតហេតុ ពេលដែលយើងរកឃើញជនដែលបានធ្វើសំណើ ឬជនសង្ស័យថារងគ្រោះទាំងនេះ ពេលដែលយកចេញមក និងប្រមូលដែលអ្នកពាក់ព័ន្ធនៅទីនោះ ខាងក្រុមការងារជំនាញទាំងបួនពិនិត្យមើល និងធ្វើការសម្ភាសន៍ជាបឋមដើម្បីកំណត់អត្តសញ្ញាណ ថាគាត់ជាជនរងគ្រោះ ឬជនងាយរងគ្រោះនៃអំពើជួញដូរមនុស្សដែលឬទេ។ ក្នុងករណីដែលសង្ស័យថាគាត់ជាជនរងគ្រោះ គឺក្រុមការងារជំនាញទាំងបួន បានសហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។ ជនដែលសង្ស័យថារងគ្រោះ ត្រូវបានសម្ភាសន៍ដើម្បីកំណត់អត្តសញ្ញាណ ហើយការកំណត់របស់យើង គឺផ្អែកទៅលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ ពាក្យថាច្បាប់អន្តរជាតិនេះ គឺជាលិខិតតុបករណ៍ ដែលជាពិធីសាបន្ថែមទៅលើអនុសញ្ញាអង្គការហប្រជាជាតិ ស្តីអំពីឧក្រិដ្ឋកម្មឆ្លងដែនដែលពិធីសានោះនិយាយអំពីការបង្ការទប់ស្កាត់ ការបង្ក្រាប និងការផ្តន្ទាទោសអំពើជួញដូរមនុស្ស ជាពិសេសលើស្ត្រីនិងកុមារ។ យើងអាចដឹងថាប៉ារ៉ាបូមបានគឺមានជាតុផ្សំបី ទី១គឺសកម្មភាព (មានការជ្រើស មានការលួងលោម មាន

ការអូសទាញ មានការដឹកជញ្ជូន-ផ្ទេរ-ប្រគល់ទទួល) ទី២គឺមធ្យោបាយ (មានការគំរាមកំហែម មានការបង្ខាំងបិតសិទ្ធិសេរីភាព រំលោភដោយអំអាច ការប្រើប្រាស់អំពើហិង្សា និងការល្បួងលោម) និងទី៣គឺយើងរកគោលបំណងពីការកេងប្រវ័ញ្ច ការធ្វើអាជីវកម្ម ការដកហូតសិរីរាង្គ ឬទម្រង់ផ្សេងៗទៀតនៃការជួញដូរមនុស្ស ជួញដូរពលកម្ម ឬអាជីវកម្មផ្លូវភេទ។ ក្នុងករណីដែលរកឃើញបែបនេះ គាត់គឺត្រូវបានចាត់ទុក្ខថាជាជនរងគ្រោះនៃអំពើជួញដូរមនុស្ស ហើយមន្ត្រីនគរបាលជំនាញប្រឆាំងការជួញដូរមនុស្ស និងស្រាវជ្រាវចាប់ខ្លួនអ្នកដែលពាក់ព័ន្ធទាំងនោះយកមកផ្តន្ទាទោសតាមច្បាប់។ ថ្មីៗនេះយើងបានរកឃើញជនរងគ្រោះដែលជាជនជាតិឥណ្ឌា១៤នាក់ បានកំណត់អត្តសញ្ញាណ និងបានបញ្ជូនទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីទទួលសេវាផ្លូវច្បាប់ និងសេវាសង្គម ព្រមទាំងគិតពីសិទ្ធិឧត្តមប្រយោជន៍របស់គាត់។ ដោយជនសង្ស័យ០៣នាក់ត្រូវបានចាប់ខ្លួនបញ្ជូនទៅតុលាកា នៅក្នុងតំណាក់ការផ្តល់សិទ្ធិ និងការសម្រេចចិត្តរបស់ជនរងគ្រោះ ក្នុងករណីដែលជនរងគ្រោះស្នើសុំបន្តនីតិវិធីទៅតុលាការ គឺសមត្ថកិច្ចយើងសម្របសម្រួលឱ្យពួកគាត់បានស្នាក់នៅ ព្រមទាំងរងចាំបណ្តោះអាសន្នពីនីតិវិធីតុលា។ តែបើពួកគាត់មិនចង់ស្នាក់នៅ គឺជាសិទ្ធរបស់ពួកគាត់ និងស្នើសុំទៅតុលាកាធ្វើកិច្ចសហការការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដោយធ្វើការសម្របសម្រួលឱ្យគាត់បានវិលត្រឡប់ទៅប្រទេសរបស់គាត់វិញ។ ប៉ុន្តែស្ថានទូតនៃប្រទេសជាសាម៉ីត្រូវសហការ ដើម្បីសម្របសម្រួលឱ្យគាត់វិលត្រឡប់មកវិញចូលមកសាវនាកា ក្នុងករណីដែលតុលាកាធ្វើការកោះហៅមកជំនុំជំរះ។ ចំណុចដែលយើងមានបញ្ហាប្រឈម ជនរងគ្រោះគាត់មិនចង់បន្តនីតិវិធីតុលាកាទេ គឺគាត់ស្នើសុំវិលត្រឡប់ទៅប្រទេសគាត់វិញ។ ក្រៅពីយើងរកមិនឃើញជាតុផ្សំប៉ារ៉ាបូមទេ ដូចដែលលោកស្រីបានលើកឡើងថា តាមការកត់សម្គាល់ពីខាងសហរដ្ឋអាមេរិក ពាក់ព័ន្ធទៅនឹង ONLICE SCAMS ដែលអាចជាករណីជួញដូរមនុស្សដែរ យើងខ្ញុំសមត្ថកិច្ចជំនាញទទួលយក ទទួលស្គាល់ ប្រសិន ONLICE SCAMS នេះយើរកឃើញជាតុផ្សំតាមប៉ារ៉ាបូម ចាត់ទុក្ខជាអំពើជួញដូរមនុស្ស តែបើសិន ONLICE SCAMS នោះយើងរកមិនឃើញជាតុផ្សំតាមប៉ារ៉ាបូម វាជាបទល្មើសព្រហ្មទណ្ឌដទៃទៀត។ កន្លងទៅយើងធ្វើកិច្ចសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធនៅកម្ពុជា ហើយកំពង់តែធ្វើកិច្ចសហការជាមួយសមត្ថកិច្ចបរទេស ដែលពាក់ព័ន្ធទៅនឹងករណីស៊ីឈ្នួលពពោះជំនួស ហេតុអ្វីបានជានៅក្នុងពេលនេះខ្ញុំជាលើកយកករណីនេះយកមកជម្រាបជូនលោកស្រី។ ពីព្រោះករណីស៊ីឈ្នួលពពោះជំនួសនេះ គឺជារឿងមួយសុំឱ្យមានការចាប់អារម្មណ៍ពីមជ្ឈដ្ឋានអន្តរជាតិ រឿងមួយស្មុគស្មាញជាងរឿង ONLICE SCAMS ទៅទៀត វាពាក់ព័ន្ធទៅនឹងកុមារដែលជាទារកតែម្តង ហើយវាអាចប៉ះពាល់ទៅដល់សន្តិសុខជាតិពិភពលោក ដែលយើងទាំងអស់គ្នាមិនគួរមើលរំលងទេ។ មានការរៀបចំ មានការចាត់ចែងជាបណ្តាញ និងជាប្រព័ន្ធពីក្រៅប្រទេស ពីប្រទេសមួយទៅប្រទេស រហូតមកដល់ប្រទេសកម្ពុជា គឺដើម្បីជាក់មេជីវិតដើម្បីស៊ីឈ្នួលពពោះជំនួស ហើយលក់ដូរទារកតែម្តង។ ខ្ញុំសូមចែកពាក់ព័ន្ធករណីនេះ ហេតុអ្វីបានជាពុំលើកឡើងជាបញ្ហាដែលយើងគួរតែរួមគ្នាធ្វើការដោះស្រាយ និងមិនគួមើលរំលងទេ គឺវាទាក់ទងនឹងការអូសទាញ ការឃោសនាតាមបណ្តាញសង្គម ហើយក៏នាំពីប្រទេសមួយទៅប្រទេសមួយផ្សេងទៀត ខ្ញុំក៏សូមលើកនៅទីនេះផងដែរដោយសារតែព័ត៌មានផ្សព្វផ្សាយជាច្រើនរួចមកហើយ។ គេដាក់មេជីវិតនៅមន្ទីរពេទ្យប្រទេសថៃ ទោះបីប្រទេសថៃមានច្បាប់ ពពោះជំនួស ក៏ប្រទេសគេរឹតបណ្តឹងនៃការប្រព្រឹត្តបទល្មើសពពោះជំនួសដែរ ហើយដែលអាចនាំទៅការជួញដូរមនុស្ស ដូច្នេះទើបគេធ្វើការគេចខ្លួនមកកម្ពុជា ហើយលាក់ខ្លួនដើម្បីឱ្យកូននឹងធំហើយបានកើត។ បន្ទាប់មកគេប្រគល់-ទទួលក្មេងនោះឱ្យទៅអ្នកដ៏ទៃ នៅក្នុងពេលនឹងយើងកំពុងរកឃើញការចរាចរផ្ទេរលុយ ពីក្រៅប្រទេសមកប្រទេសកម្ពុជា ដើម្បីចាត់ចែងក្នុងការពពោះនេះ។ គេមានបណ្តាញនៅកម្ពុជាផងដែរ ដើម្បីធ្វើការថែទាំកូន និងរកទីកន្លែងស្នាក់នៅតាមរយៈការលាក់បំពួន ក៏ដូចជាមានការទទួលយកលុយដើម្បីប្រគល់ទៅឱ្យអ្នកដែលស៊ីឈ្នួលពពោះជំនួសដែលជាម្តាយ ចំពោះការទទួលលុយមានតាំងពីដំណាក់កាលដំបូងចំនួនប្រាំបីរយដុល្លារសហរដ្ឋអាមេរិកក្នុងម្នាក់ ហើយវាជាការព្រមព្រាងគ្នានៅពេលដែលកូនកើតចេញមកហើយ គឺបាន

មួយម៉ឺនពីរពាន់ប្រាំរយដុល្លារសហរដ្ឋអាមេរិកក្នុងម្នាក់។ សមត្ថកិច្ចយើងកំពង់តែមានការព្រួយបារម្មណ៍ ដោយសារតែការឆ្លើយរបស់ពួកគាត់ថាអត់ដឹងយកកូនទៅណា ប៉ុន្តែតាមការរកឃើញរបស់យើង គឺយកទៅក្រៅប្រទេស។ ហើយអ្នកចំណាយការចាត់ចែងអាចចំណាយពីប្រាំមួយម៉ឺនដុល្លារសហរដ្ឋអាមេរិក ទៅដល់ដប់ម៉ឺនដុល្លារសហរដ្ឋអាមេរិក។ អ្វីដែលជាសមត្ថកិច្ចកម្ពុជាមានការព្រួយបារម្មណ៍ និងកង្វល់ពាក់ព័ន្ធទៅនឹងការធ្វើបុរេវិនិច្ឆ័យ។ សូមបន្ថែមជូនថាក្រោយដែលយើងធ្វើកិច្ចការនេះ ខាងកម្ពុជាក៏បានធ្វើសេចក្តីជូនដំណឹងទៅស្ថានទូតហ្វីលីពីន ចំណុចដែលសំខាន់ថាសមត្ថកិច្ចកម្ពុជាបានចូលរួមសម្របសម្រួលជាមួយស្ថាប័នអយ្យការ និងតុលាការ។ ជាការពិតមានមជ្ឈដ្ឋានផ្សេងៗបានលើកឡើងថា ការស៊ីឈ្នួលពពោះជំនួសនេះ បើយើងចាត់វិធានការទៅលើម្តាយវាប៉ះពាល់ទៅលើសិទ្ធិរបស់ពួកគាត់ ហើយសួរថាការ តើការពពោះជំនួសមានអ្វីខុស សម្រាប់ការពពោះអត់មានអីខុសទេ ប៉ុន្តែអ្វីដែលជាអំពើខុសច្បាស់គឺការលក់ដូរទារក លក់ដូរមនុស្ស ហើយមានចែងនូវច្បាប់មាត្រាទី១៣និងទី១៤ ដែលសហរដ្ឋអាមេរិកកំណត់យក។ ក្រោយពេលដែលយើងរកឃើញបែបនេះម្តាយនិងកូនមិនត្រូវបានដាក់ពន្ធនាគារទេ ចំណុចនេះគឺគោរពសិទ្ធិដោយយើងបានពិភាក្សាជាមួយព្រះរាជអាជ្ញា និងតុលាការ ក៏ដូចជាបញ្ជូនគាត់ទៅមន្ទីរពេទ្យរបស់នគរបាល ១៦ឧសភា ដើម្បីថែទាំសុខភាព ដើម្បីការពារគាត់ពីការយាយីពីបណ្តាញនៅពេល ដែលកូនគាត់បានកើតមក។ ស្ថានទូតហ្វីលីពីនក៏ទទួលស្គាល់ថាជាបទល្មើសលក់ដូរមនុស្ស ក្រោយមកក៏មានស្នើសុំឱ្យលើកលែងទោសទៅព្រះមហាក្សត្រកម្ពុជា ហើយសមត្ថកិច្ចកម្ពុជាបានធ្វើការសម្របសម្រួលក្រោយពីបានការលើកលែងទោស ឱ្យពួកគាត់បានវិលត្រឡប់ទៅប្រទេសគាត់វិញ។

លោកស្រី **Kelly Geoghengan** បានថ្លែងអំណរគុណដល់ឯកឧត្តម ជីវ ផល្លី ក្នុងករណីសិក្សាបង្ហាញព័តមានដូចដែលបានលើកឡើងខាង វាបានជួយឱ្យនាងខ្ញុំយល់ដឹងទាក់ទងទៅនឹងទិដ្ឋភាព និងការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការដោះស្រាយបញ្ហានៃអំពើជួញដូរមនុស្ស។ ខ្ញុំទទួលស្គាល់ថាវាជាបញ្ហាដ៏ស្មុគស្មាញ ប៉ុន្តែអធ្យាស្រ័យផងខ្ញុំយល់ឃើញថាបញ្ហានេះ គឺវាបានកើតឡើងតាំងពីឆ្នាំ២០១៦មកម្លេះ ប៉ុន្តែមួយរយៈក្រោយមកវាសាបរលាភទៅវិញ ហើយយើងសង្កេតឃើញថ្មីៗនេះវាកើតឡើងជាថ្មីម្តងទៀត ការយល់ឃើញរបស់នាងខ្ញុំការជួញដូរការពពោះនេះវាលេចចេញជារូបរាង ភិនភាគ និងវិកាលដាលកាន់តែធំជាងមុន តើឯកឧត្តមយល់ឃើញយ៉ាងម៉េចដែរ?

ឯកឧត្តម ជីវ ផល្លី បានឆ្លើយតបទៅនឹងលោកស្រីបន្តទៀត តាមព័ត៌មានដែលយើងទទួលបាន វាអាចនឹងកើតឡើង និងកើនឡើង ដោយសាតែថ្មីៗនេះមានព័ត៌មានករណីពពោះជំនួសនៅថៃ ហើយការរៀបចំឯកសានឹងវាមិនដឹងថាចេញមកពីណាទេ។ ករណីនេះយើងកំពុងធ្វើកិច្ចសហការជាមួយភាគីថៃ ថាតើឯកសានោះវាពិតពិនណាដែលយើងកំពង់ស្នើឱ្យភាគីថៃឱ្យបញ្ជាក់ ដោយសាគាត់ចេញពីពេទ្យពពោះហើយ អត់ចេញទៅប្រទេសថៃទេ មានន័យថាគាត់អត់ធ្វើដំណើរតាមយន្តហោះចេញពីប្រទេសថៃទេ បែជាធ្វើដំណើរតាមផ្លូវគោកមកប្រទេសកម្ពុជាវិញ។ ដោយការចេញដំណើរពីខេត្តសៀមរាប តាមយន្តហោះ ដោយហេតុនេះទើបនគរបាលអន្តោប្រវេសន៍កម្ពុជាមានការសង្ស័យ និងធ្វើការប្រមូលភស្តុតាងលើករណីនេះ។ ប៉ុន្តែដោយសាតែមានកិច្ចសហការមានការលំបាក ត្រូវការនីតិវិធីវែងឆ្ងាយ តាមការណែនាំរបស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកិច្ចការយុត្តិធម៌ គឺយើងបានអនុញ្ញាត្តិឱ្យគាត់បានទៅ ប៉ុន្តែនីតិវិធីរបស់យើងនូវត្រូវបន្តកិច្ចសហការជាមួយសមត្ថកិច្ចថៃក្នុងការផ្ទៀងផ្ទាត់ព័ត៌មាន និងឯកសាពាក់ព័ន្ធមួយចំនួនទៀត។

លោកជំទាវអនុប្រធានអចិន្ត្រៃយ គ.ជ.ប.ជ បានចូលរួមបញ្ជាក់បន្ថែមទៀតថា ដែលលោកស្រីបានសួថា តើការរកឃើញការពពោះថ្មីបានកើតឡើង ទើបយើងមានការចាប់អារម្មណ៍? ខ្ញុំចង់និយាយថាវាកើតតាំងពីឆ្នាំ២០១៦មកម្លេះ តែដោយលោកស្រីបានលើកឡើង គឺជាករណីដំបូងដែលយើងបានរកឃើញនៅប្រទេសកម្ពុជា ដោយសារតែមានក្រុមហ៊ុនចេញពីប្រទេសថៃ មកធ្វើការជ្រើសរើសស្ត្រីដើម្បីពពោះនៅកម្ពុជា ប៉ុន្តែដំណាក់កាលនោះយើងបាន

ចាត់ទុកថាស្ត្រីគឺជាជនរងគ្រោះ តែដោយសារតែស្ត្រីទាំងនោះអត់បានដឹងថា តើការពពោះនោះដើម្បីអ្វី គ្រាន់តែពពោះជួយឱ្យគេទេ។ យើងក៏បានរកឃើញថាមានការកើនឡើងនូវចំនួនស្ត្រី ដែលនឹងស្ម័គ្រចិត្តពពោះ បានរកឃើញជាបន្តទៀត នៅឆ្នាំ២០១៨ គឺមានស្ត្រីនៅតាមរោងចក្រ និងបណ្តាសហគ្រាស ដោយមានការស្ម័គ្រចិត្តធ្វើការពពោះជួច្នេះហើយក្រសួងមហាផ្ទៃបានកំណត់ជាវិធានការថ្មី ថានេះមិនមែនជាជនរងគ្រោះទេ ដោយសារតែគាត់បានឃុបឃិតជាមួយជនល្មើស ក្នុងការពពោះ និងលក់កូនឱ្យគេ។ នៅពេលដែលយើងសម្រេចថាធ្វើការផ្តន្ទាទោស គេសួថាតើយកច្បាប់អ្វីដើម្បីដាក់ទោស ពីព្រោះអត់មានច្បាប់ ស្តីពីការពពោះជំនួសនៅឡើយ ហេតុនេះហើយទើបកម្ពុជាប្រើប្រាស់ច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដោយសារតែមានមាត្រាច្បាស់លាស់បញ្ជាក់ពីការជួញដូរមនុស្ស ឬការនាំចេញអនីតិជនដោយខុសច្បាប់ ដោយមានបំណង មានគោលដៅ និងមានការឆ្លងដែន ទើបយើងអនុវត្តបាន។ យើងគិតថាការអនុវត្តនេះមិនខុសឆ្គងទេ ដោយសារតែកូននោះត្រូវបានគេយកទៅលក់ហើយអ្នកដែលឃុបឃិត តាមច្បាប់កម្ពុជាគឺត្រូវតែមានទោស រីឯម្តាយក៏មានទោសដែរ ពីព្រោះពួកគាត់បានទទួលលុយក្នុងការទិញទារក ដែលជារឿងឃុបឃិតគ្នា។ នៅពេលដែលយើងបានដាក់ច្បាប់បែបនេះ គឺមានការថយចុះប៉ុន្តែក្នុងឆ្នាំ២០២៤កន្លងទៅនេះ បានរកឃើញករណីថ្មីបានលេចចេញសាជាថ្មី គឺជាជនបរទេស (ហ្វីលីពីន) តាមពិតមិនមែនចំនួន១៣នាក់ទេ គឺ២០នាក់ ប៉ុន្តែក៏មានជនជាតិវៀតណាមចំនួន០៤នាក់ទៀតដែរ ប៉ុន្តែតែក្នុងនោះហេតុអីក៏ដាក់ទោសតែ១៣នាក់ គឺដោយសារនាក់ទាំងនេះបានទទួលការពពោះរួចហើយ ចំណែកឯស្ត្រីហ្វីលីពីន០៧នាក់និងស្ត្រីវៀតណាម០៤នាក់ទៀត មិនបានដាក់ទោសទេដោយសារតែគាត់មិនទាន់បានពពោះនូវឡើយ គឺគ្រាន់តែធ្វើការបណ្តេញចេញ។ បច្ចុប្បន្ននេះយើងក៏បានរកឃើញបន្ថែមទៀត ដោយបានការដាក់ការសង្ស័យទៅបញ្ហា ដែលមានស្ត្រីចេញទៅរកគូស្រករនៅក្រៅប្រទេស ប៉ុន្តែពាក់ព័ន្ធដែលមានកូន មានផ្ទៃពោះ រួចហើយត្រឡប់មកវិញ ដែលអាចពាក់ព័ន្ធករណីជួញដូរទារកតាមរយៈនេះ ទើបយើងគិតថាមានកំណើនគួឱ្យព្រួយបារម្ភ។ សូមបញ្ជាក់បន្ថែមទៀតថា នៅប្រទេសហ្វីលីពីនការផ្សព្វផ្សាយ ការជ្រើសរើសឱ្យស្ត្រីពពោះធ្វើឡើងជាសាធារណៈ ចឹងហើយគិតថាមិនមានតែប៉ុណ្ណឹងទេ ដែលធ្វើការពពោះមកលាក់ខ្លួននៅកម្ពុជា។

លោកស្រី **Kelly Geoghengan** បានអរគុណដល់ឯកឧត្តម **ជីវ ផល្លី** ចំពោះព័ត៌មានដែលបានលើកឡើងទាក់ទងទៅនឹងការចាត់វិធានការទាន់ពេល ខ្ញុំទទួលស្គាល់ថា ទាក់ទងទៅនឹងបញ្ហាស្ត្រីពពោះទារកនេះ គឺមានបញ្ហាស្មុគស្មាញមែន ប៉ុន្តែចំណុចដែលខ្ញុំចង់លើកឡើង គឺជំហ៊របស់សការីរបស់ខ្ញុំនៅវ៉ាស៊ីនតោន ដែលគាត់មើលឃើញថាទាក់ទងនឹងការឆបោកតាមប្រព័ន្ធអនឡាញ គឺមានធាតុផ្សំជាច្រើនដែលអាចកើតឡើងជាបទល្មើសជួញដូរមនុស្ស។ ហើយដែលយើងអាចបញ្ជាក់ឱ្យបានច្បាស់ថា តើករណីយ៉ាងណាដែលយើងបែងចែកឱ្យដាច់ ថាវាជាករណីឆបោកតាមប្រព័ន្ធអនឡាញ វាមិនមែនជាករណីជួញដូរមនុស្សទេ វាពិតជាល្អ។ មូលហេតុចំណុចមួយ ដែលខ្ញុំចង់លើកឡើងដូចដែលឯកឧត្តមលើកឡើងពីជនជាតិឥណ្ឌាចំនួន១៤នាក់ ដែលបានធ្វើការដោះស្រាយហើយ គឺជាការល្អ ប៉ុន្តែទំហំការឆបោកតាមប្រព័ន្ធអនឡាញ និងការជួញដូរមនុស្ស វាមានទាក់ទំនងគ្នាយ៉ាងណា ខ្ញុំទទួលស្គាល់វាអាចចាត់ចូលជាបទល្មើសផ្សេងទៀត ដូចជាការបង្ខាំង ប៉ុន្តែមានករណីមួយចំនួនដែលឆ្លើយតបទៅនឹងធាតុផ្សំទាំងបី នៅក្នុងពិធីសារប៉ាឡាំបូម ដូចជាការបង្ខំឱ្យគាត់ធ្វើការ ការធ្វើទារុណកម្ម ការដកហូតទូរស័ព្ទ ការដកលិខិតឆ្លងដែន ទាំងនេះវាចូលទៅនឹងបទល្មើសដោយបង្ខំ។ ទាក់ទងទៅនឹងមធ្យោបាយ ដោយសារតែគាត់ត្រូវបានគេដកហូតលិខិតឆ្លងដែនវាមានករណីដែលខាងវ៉ាស៊ីនតោនចង់លើកឡើង ចំពោះជនរងគ្រោះចង់ដាក់ពាក្យបណ្តឹង តើយើងមានការបែងចែកដូចម្តេច មានធាតុផ្សំឆ្លើយតបនឹងបទល្មើសហើយ ប៉ុន្តែជនរងគ្រោះមិនអាចមានលទ្ធភាពក្នុងការដាក់ពាក្យបណ្តឹងចំណោះករណីនេះតើយើងត្រូវធ្វើការចូលឆែកឆេរ ឬធ្វើការដោះស្រាយបានអត់។ ខ្ញុំចង់ថែមចំណុចមួយចំនួនទៀតដូចដែលឯកឧត្តម លោកជំទាវ បានជ្រាបតាមសាព័ត៌មាន គឺមានការផ្លាស់ប្តូរមួយចំនួនទាក់ទងនឹងរាជរដ្ឋាភិបាល

របស់យើង។ ខ្ញុំមិនប្រហែលជាអាចរំពឹងទុកថាក្នុងរដ្ឋបាលថ្មីនេះ អាចបកស្រាយបញ្ហាណាដែលខុសពីរដ្ឋបាលមុននោះទេ អ្វីដែលរដ្ឋបាលថ្មីបានផ្តោតសំខាន់នោះ គឺធ្វើយ៉ាងណាឱ្យសហរដ្ឋអាមេរិកកាន់តែមានសុវត្ថិភាពជាងមុន មានសុខសន្តិភាពជាងមុន មានភាពរីកចម្រើនជាងមុន។ ហើយទាក់ទងទៅនឹងការឆបោកតាមប្រព័ន្ធអនឡាញ វាអាចចូលទៅនឹងជាតុមួយ ដែលអាចប៉ះពាល់ទៅនឹងសុខសន្តិភាពរបស់សហរដ្ឋអាមេរិក ប៉ុន្តែខ្ញុំចង់លើកឡើងពាក់ព័ន្ធទៅនឹងការជួញដូរមនុស្ស ដោយសារតែរបាយការណ៍ជួញដូរមនុស្សនេះ គឺបានចែងដោយសភាសហរដ្ឋអាមេរិក ហើយសភាសហរដ្ឋអាមេរិកកំណត់ច្បាប់នេះឱ្យស្ថានទូតទាំងអស់ ប្រមូលព័ត៌មានទាក់ទងនឹងរបាយការណ៍ការជួញដូរមនុស្ស។ ក្នុងចំណុចរបាយការណ៍នេះដែរ នៅពេលដែលរបាយការណ៍នេះចេញ ហើយត្រូវបានកំណត់ ទី១ត្រូវបានវាយតម្លៃដោយស្ថិតនៅក្នុងលេខរៀង និងទី២វាអាចជាប់ពាក់ព័ន្ធទៅនឹងចំនួនបរទេសដែលត្រូវបានផ្តល់មក។ ខ្ញុំគិតថាករណីប្រទេសកម្ពុជាល្អមួយ ពិសេសមួយ ដោយសារតែយើងឃើញមានទំនាក់ទំនងកាន់តែល្អប្រសើរ រវាងសាម៉ីប្រទេសទាំងពីរ។ ខ្ញុំសង្ឃឹមថាទំនាក់ទំនងដ៏ល្អនេះនឹងនូវតែបន្តទៀត ហើយបទល្មើសជួញដូរមនុស្សនេះ មិនព្យាយាមឱ្យមានភាពរាំងស្ទះនៃទំនាក់ទំនងដ៏ល្អរបស់ប្រទេសទាំងពីរឡើយ។ ខ្ញុំសូមសំដែងការអរគុណដល់លោកជំទាវ ជូ ប៊ុនអេង ដែលតែងតែព្យាយាមជួយសម្របសម្រួលក្នុងការកិច្ចប្រជុំ និងសូមអរគុណចំពោះឯកឧត្តម លោកជំទាវនៅក្នុងកិច្ចប្រជុំនេះផងដែរ។

ឯកឧត្តម **ជីវ ផល្លី** បានចូលរួមយោបល់បន្ថែមទៀត យើងមានកិច្ចសហការជាមួយអង្គការជាង៣០ ហើយរាងរាល់មួយខែប្រជុំម្តង ដើម្បីដកបទពិសោធ៍ រកចំណុចខ្សោយ រកបញ្ហាប្រឈម រកដំណោះស្រាយ ក្នុងការធ្វើកិច្ចសហការ និងជួយគ្នាទៅវិញទៅមកក្នុងវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់។ ប៉ុន្តែដោយសារតែមួយរយៈពេលនេះ មានកិច្ចការច្រើនទើបលើកពេលកិច្ចប្រជុំក្នុងរយៈពេលបីខែម្តងវិញ។ ទាក់ទងទៅនឹងការជួយសង្គ្រោះដល់អនីតិជន ដែលស្ថិតនៅក្នុងវិស័យសេវាកម្ម យើងតែងតែនិយាយថាសេវាកម្មផ្លូវភេទ គឺវាមានការលំបាក មានបញ្ហាប្រឈម តែជាកិច្ចខិតខំប្រឹងប្រែងរវាង អង្គការមិនមែនរដ្ឋាភិបាលជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ក្នុងការអនុវត្តច្បាប់ គឺយើងតែងតែឃ្លាំមើល និងដាក់កម្លាំងទៅតាមកន្លែងកម្សាន្ត ហើយបានរកឃើញ និងមានជាអនីតិជនយើងក៏បានធ្វើការស្នើគោលការណ៍ថ្នាក់ដឹកនាំ និងព្រះរាជអាជ្ញា ដើម្បីធ្វើការបង្ក្រាប។ ហេតុអ្វីបានជានៅក្នុងរបាយការណ៍ ឃើញមានអនីតិជនច្រើន ដោយសារតែក្នុងការបង្ក្រាបករណីសញ្ចារកម្មមួយករណី មានអនីតិជនអាយុពី១៥-១៧ឆ្នាំ មានចំនួនពី៣នាក់ដល់ទៅ១០នាក់។ ត្រង់ចំណុចនេះយើងជួយកុមារពីការធ្វើអាជីកម្មផ្លូវភេទ បានច្រើន ហើយកុមារទាំងអស់នោះពេលដែលបានជួយរួចហើយ បានប្រគល់ទៅសង្គមកិច្ចរបស់រដ្ឋ បន្ទាប់ទៅប្រគល់ទៅឱ្យអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្តល់សេវា ព្រមទាំងបណ្តុះបណ្តាលបំណិនជីវិត និងវិជ្ជាជីវៈ ដើម្បីកុំឱ្យពួកគាត់ក្លាយទៅជាកុមាររងគ្រោះទៀត។

ឯកឧត្តម ហ៊ិន ភក្តី អគ្គនាយករង ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានធ្វើការបង្ហាញពីភារតួនាទី និងភារកិច្ចរបស់ក្រសួងសង្គមកិច្ច ដែលជាសេនាធិការរាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រសួងមានតួនាទីផ្តល់សេវដល់ជនរងគ្រោះ និងសមាហរណកម្មទៅប្រទេសដើម្បីវិញ ចំពោះជនរងគ្រោះដែលជាជនបរទេស និងជនរងគ្រោះជាជនជាតិខ្មែរយើងធ្វើសមាហរកម្មទៅសហគមន៍វិញ។ ក្នុងនោះដែរបន្ទាប់ពីខាងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានធ្វើការកំណត់អត្តសញ្ញាណជនរងគ្រោះរួច ក្រសួងនឹងធ្វើកិច្ចសហការជាមួយអង្គការដៃគូមួយចំនួន ដែលមានMOU ជាមួយក្រសួង ដើម្បីផ្តល់សេវាដល់ជនរងគ្រោះទៅតាមអង្គការផ្សេងៗ ក្នុងនោះយើងបែងចែកជនរងគ្រោះទៅតាមអង្គការដែលអាចទទួល។

ក្នុងនោះដែលលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានបន្ថែមទៅលើកការបកស្រាយ របស់ឯកឧត្តមក្រសួងសង្គមកិច្ច ទាក់ទងទៅនឹងកិច្ចការពារជនរងគ្រោះ ដោយសាឥលូវនេះយើងកំពុងតែរៀបចំកែសម្រួលគោល

ការណែនាំ ស្តីពីទម្រង់រួមនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដែលចាប់ផ្តើមពីដូចដែលឯកឧត្តម ជីវ ផល្លី បាន លើកឡើង ពីការស្តេមបឋម រហូតដល់យើងត្រូវបញ្ជូនករណីនេះទៅតុលាការ។ ក្នុងដំណាក់ការនេះ គឺចង់ឱ្យជនរងគ្រោះទទួលបានសេវា ការងារនេះយើងបានសហការជាមួយអង្គការ JICA និងដៃគូពាក់ព័ន្ធ ក្រោមការដឹកនាំសម្របសម្រួលពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមានអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គឺរូបនាងខ្ញុំបានចូលរួមផងដែរ។ នៅក្នុងដំណាក់កាលបឋម ដែលយើងគិតថានៅក្នុងឆ្នាំ២០២៥នេះ និងត្រូវដាក់ឱ្យអនុវត្តសាកល្បង ម្យ៉ាងវិញទៀតវិស័យខាងសង្គមកិច្ចនេះដែរ ដោយសារតែយើងមើលឃើញថាមានវិស័យពាក់ព័ន្ធនឹងសង្គមកិច្ចច្រើន ក្រសួងសង្គមកិច្ចក៏មានសាលាបណ្តុះបណ្តាលភ្នាក់ងារសម្រាប់ការផ្តល់វិស័យសង្គមកិច្ច យើងមើលឃើញថាតិចទៀត និងមានការពង្រីកទៅដល់សហគមន៍ និងពិភាក្សាជាមួយសាលាដាក់បញ្ចូលវិស័យសង្គមពាក់ព័ន្ធនឹងការជួញដូរមនុស្សផងដែរ។ នេះជាការរីកចម្រើនថ្មី ដែលកម្ពុជាបាននឹងកំពុងតែយកចិត្តទុកដាក់ក្នុងការផ្តល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ ដូច្នេះនូវទីបបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវត្តមានលោកស្រី **Kelly Geoghengan** ដែលបានផ្តល់នូវព័ត៌មានជាច្រើនសម្រាប់ពួកយើងខ្ញុំនឹងបានទទួលនូវភាពច្បាស់លាស់ នូវក្នុងការផ្តល់នូវព័ត៌មានអ្វីដែលយើងបានធ្វើ គឺកម្ពុជាកំពង់តែប្រមូលនូវរបាយការណ៍ទូទៅ ប៉ុន្តែអ្វីដែលសហរដ្ឋអាមេរិកចង់បាន គឺដើម្បីធ្វើការវាយតម្លៃ និងគន្លឹះមួយចំនួនដែលចង់ដឹង ដូចនេះហើយយើងបានដឹងច្បាស់ហើយថាអាមេរិកចង់បានរបៀបណា នោះហើយយើងនិងព្យាយាមកែសម្រួលនូវរបាយការណ៍របស់យើង។ កិច្ចប្រជុំពិភាក្សា បានបញ្ចប់នាវេលាម៉ោងដប់ និងសែសិបនាទី ថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាស សោមនស្សរីករាយ និងស្និទស្នាលជាទីបំផុត។

ថ្ងៃចន្ទ ១២រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

*រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៥*

**អ្នកកត់ត្រា**

វរសេនីយ៍ទោ ចេក វណ្ណា

បានពិនិត្យ និងសូមគោរពជូន

*លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។*

*រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៥*

**ប្រធានលេខាធិការដ្ឋានរដ្ឋបាល សរុប**

វរសេនីយ៍ឯក. មូរ ជាវិត

យល់ព្រម

២៥/០២/២០២៥

ឧត្តមសេនីយ៍ឯកវេជ្ជ.ប៉ុណ្ណ សំខាន់